# ពន្ធនាគារក្រុង Seattle

## សំនួរដែលសួរញឹកញាប់

**1. ហេតុអ្វីក៏យើងត្រូវការពន្ធនាគារសំរាប់បទល្មើសមជ្ឈឹម ? មានជនជាតិអាមេរិកជាច្រើន ត្រូវបានចាប់ដាក់ពន្ធនាគារ ។**

ក្រុងបានកាត់បន្ថយចំនួនអ្នកទោសបទល្មើសមជ្ឈឹមបានចំនួន 38% ក្នុងរយៈពេល 10 ឆ្នាំកន្លងមកនេះ ។ ក្រុងកំពុងតែបន្តធ្វើការកាត់ បន្ថយចំនួនមនុស្សដែលត្រូវជាប់ពន្ធនាគារពីបទល្មើសមជ្ឈឹម ។ ទោះយ៉ាងណាក៏ដោយ ច្បាប់រដ្ឋតម្រូវថាជនល្មើសមួយចំនួន ដូចជាជនដែលមានប្រវត្តិបើកបរបន្ទាប់មតទ្ធិពលបន្ទប្បឹងស្រវឹង ត្រូវតែចាប់ដាក់ពន្ធនាគារ ។ ច្បាប់ក៏បានចែងឱ្យសរសេរចូលទៅក្នុងបញ្ជី ព្រមទាំងកំណត់រយៈពេលជាប់ពន្ធនាគារ ចំពោះជនទាំងឡាយណាដែលចោទប្រកាន់ពីបទអំពើហិង្សាក្នុងគ្រួសារ ។ សុវត្ថិភាពសាធារណៈបានកំណត់ថា ក្រុងត្រូវតែចាប់ដាក់ពន្ធនាគារ ចំពោះជនដែលប្រព្រឹត្តិល្មើស ដើម្បីការពារការគំរាមកំហែងដល់ជនដទៃ ។ ជាងនេះទៅទៀត មួយភាគបីនៃជនដែលជាប់ពន្ធនាគារ ត្រូវបានអប់រំកែប្រែ ឬដោះលែងពីពន្ធនាគារ - ប៉ុន្តែក្រោយមកមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយជាលទ្ធផលត្រូវចាប់ខ្លួន និងមានឈ្មោះក្នុងបញ្ជីជាថ្មីម្តងទៀត ។

**2. ហេតុក៏យើងមិនចាប់ដៃគូជាមួយនឹងទីក្រុងផ្សេងទៀតក្នុងខោនធី ? ខ្ញុំលឺថា ទីក្រុង Renton, Kent និង Federal Way កំពុងតែសាងសង់ពន្ធធនាគារ ។ ហេតុអ្វីក៏មិន សហការជាមួយទីក្រុងទាំងនោះ?**

ដើម្បីឆ្លើយតទៅនឹងតម្រូវការ 20 ឆ្នាំក្រោយ ទីក្រុងនានារបស់ខោនធីភាគខាងត្បូងបានប៉ាន់ប្រមាណថា ពួកគេចាំបាច់ត្រូវសាងសង់ពន្ធនាគារដែលមាន 800 បន្ទប់ (ជិតពីរដងធៀបនឹងអ្វីដែលទីក្រុង Seattle ត្រូវការ) ។ វាពិតជាមានការពិបាក ក្នុងការស្វែងរកទីតាំងឱ្យទូលាយ ដីម្បីដាក់អ្នកទោសទាំងនៅទីក្រុង Seattle និងខោនធីភាគខាងត្បូង ។ ហើយវាក៏ពិបាកផងដែរ ក្នុងកាស្វែងរកទីតាំងភូមិសាស្ត្រដែលមានភាពងាយស្រួលសំរាប់ទីក្រុងទាំងអស់ ។ យើងកំពុងតែជួបប្រជុំជាមួយនឹងទីក្រុងនានា ដែលមកពីភាគខាងជើង និងខាងកើតខោនធី King ស្តីការសាងសង់ពន្ធនាគារជាមួយគ្នា ។ ទីក្រុងទាំងនោះ ជឿថា ពួកគេត្រូវការតែប្រមាណជា 200 បន្ទប់ប៉ុណ្ណោះក្នុងរយៈពេលជាង 20 ឆ្នាំក្រោយ ។

**3. ពន្ធនាគារថ្មីត្រូវការចំណាយច្រើន ។ តើក្រុងត្រូវចំណាយសោហ៊ុយទាំងនោះដោយរបៀបណា ?**

យើងមិនទាន់ដឹងនៅឡើយទេថា ពន្ធនាគារថ្មីនោះត្រូវចំណាយអស់ប្រាក់ប៉ុន្មាន ។ មុនពេលយើងអាចប៉ាន់ស្មានពីការចំណាយ ក្រុងត្រូវតែជ្រើសរើសទីតាំង និងរៀបចំប្លង់ ។ ក្រុង Seattle មានលទ្ធភាពលក់សញ្ញាប័ណ្ណ ដើម្បីចំណាយទៅលើការសាងសង់ពន្ធនាគារថ្មី ហើយបង់សងសញ្ញាប័ណ្ណទាំងនោះ ដោយយកប្រាក់ចំណូលដែលខ្លួនមាន ។

**4. តើវាមិនចំណាយខ្ពស់ទេម៉ែនទេ ដើម្បីប្រតិបត្តិការលើពន្ធនាគារមួយ ? តើក្រុងត្រូវចំណាយដោយរបៀបណា ? តើក្រុងត្រូវតំឡើងពន្ធមែនទេ ?**

យើងបានចំណាយលើការដាក់ពន្ធនាគារអ្នកទោសរបស់យើងនៅពន្ធនាគារខោនធី King និង Yakima រួចហើយ ដូច្នេះយើងមិនរំពឹងថា នឹងមានការប្រែប្រួលច្រើននោះទេលើការចំណាយប្រតិបត្តិការ ។ ការចំណាយប្រតិបត្តិការលើពន្ធនាគារ ត្រូវដកចេញពីចំណូលពន្ធក្នុងទីក្រុងដែលមានស្រាប់ ។ ចំពោះនិយោជិកបម្រើការងារក្នុងពន្ធនាគារក្រុង យើងមិនសំរេចចិត្តនៅឡើយទេ ថាតើត្រូវជួលបុគ្គលដោយផ្ទាល់ ឬត្រូវចុះកុងត្រាជាមួយខោនធី ដើម្បីផ្តល់និយោជិកបានត្រឹមត្រូវ ។

**5. ពន្ធនាគារធ្វើឱ្យប្រជាជនខ្លាចរអា ។ តើអ្នកត្រូវសម្របសម្រួលសាងសង់ពននាគារនៅចំកណ្តាលសង្កាត់ដោយរបៀបណា ? ប្រជាជននឹងខ្លាចមិនហ៊ានដើរចេញក្រៅ ។**

ក្រុងមានតួនាទីរក្សាសុវត្ថិភាពសហគមន៍ ។ ក្នុងអំឡុងពេលរកមើលទីតាំងដែលមានសក្តានុពល យើងបានកំណត់ការស្រាវជ្រាវទីតាំងទាំងឡាយណាដែលជាកន្លែងឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ ឬទីតាំងប្រើប្រាស់សំរាប់បោះទំនិញរាយ ។ ពេលមនុស្សភាគច្រើនគិតពីពន្ធនាគារ ពួកគេនឹកគិតទៅដល់បទល្មើសធំៗ ។ ប៉ុន្តែ នោះមិនមែនជាគំនិតត្រឹមត្រូវនៃចំនួនបទល្មើសមជ្ឈឹមរបស់ទីក្រុងឡើយ ។ អ្នកទោសជាទូទៅមានអាយុ 37 ឆ្នាំ ដែលកំពុងតែរងចាំការកាត់ទោស ក្រោមបទចោទប្រកាន់មិនពាក់ព័ន្ធនឹងអំពើហិង្សា ដែលជាមធ្យម ត្រូវជាប់ពន្ធនាគាររយៈពេល 10 ថ្ងៃ ។ ភាគច្រើនបំផុតគ្មានបទចោទប្រកាន់ណាផ្សេងទៀតដែលរង់ចាំចោទពួកគេ នៅកន្លែងផ្សេងទៀតនោះទេ ។

ការសិក្សាមួយរបស់ក្រសួងយុត្តិធមិអាមេរិក បានធ្វើការត្រួតពិនិត្យទីតាំងពន្ធនាគារចំនួនប្រាំពីរកន្លែងខុសៗគ្នា ក្នុងរដ្ឋចំនួនបួន ហើយរកឃើញថា មិនមានភាពខុសគ្នាចាំបាច់ណាមួយឡើយពាក់ព័ន្ធទៅនឹងអត្រាបទល្មើស រវាងសង្កាត់ដែលមានពន្ធនាគារ ធៀបទៅនឹងសង្កាត់ដែលគ្មានពន្ធនាគារ (ហើយមានករណីខ្លះទៀត អត្រាបទល្មើសថែមទាំងមានកម្រិតទាបទៀតផង) ។ ដោយមិនគិតពីទីតាំងចុងក្រោយដែលត្រូវសាងសង់ពន្ធនាគារ ទីក្រុង Seattle បានប្តេជ្ញាសាងសង់ពន្ធនាគារដែលមានលក្ខណៈសមស្រប និងឱ្យក្លាយទៅជាសង្កាត់មួយដែលមានសុវត្ថិភាព ។

**6. តើពន្ធនាគារថ្មីនឹងមានរូបរាងដូចម្តេច ?**
យើងមិនទាន់ដឹងទេ ។ យើងមិនអាចចាប់ផ្តើមរៀបចំគូរប្លង់ទេ រហូតដល់យើងបានជ្រើសរើសទីតាំងរួចរាល់ ។

**7. ហេតុអ្វីបានជាក្រុងត្រូវការទីតាំងមានផ្ទៃដីចាប់ពី 7 អេឃើឡើង ? ហេតុអ្វីក៏មិនសាងសង់ឱ្យខ្ពស់ ?**
ការចំណាយទៅលើផ្ទៃដី ការសាងសង់ និងប្រតិបត្តិការ មានលក្ខណៈខុសគ្នាទៅតាមការរៀបចំប្លង់ជម្រើសអាគារខ្ពស់ និងអាគារទាប ។ ផ្អែកទៅការសិក្សាស្រាវជ្រាវ និងវិភាគ ទីក្រុង Seattle ជឿថាពន្ធនាគារដែលមានកម្ពស់ទាបគឺមានសុវត្ថិភាពជាងសំរាប់បុគ្គលិក និងទណ្ឌិត ហើយចំណាយអស់តិចជាងលើការសាងសង់ និងប្រតិបត្តិការ ។ ទីក្រុង Seattle ក៏បានជួលទីប្រឹក្សាម្នាក់ឱ្យជួយវាយតម្លៃលើការសន្និដ្ឋាននេះផងដែរ ។ ក្រុងរំពឹងថាទទួលបានព័ត៌មាននេះនៅខែ កក្កដា ឆ្នាំ 2008 ។

ចំពោះអាគារដែលមានកម្ពស់ទាបនេះ ត្រូវការផ្ទៃដីចំនួន 7 អេឃើ ។ តាមការសិក្សារបស់ Ricci Greene Associates បានប៉ាន់ប្រមាណថា អាគារដែលមានកម្ពស់ទាបនេះនឹងស៊ីផ្ទៃដីចំនួន 188,000 ហ្វីតការេ ។ ដូច្នេះវាមានន័យថាត្រូវការផ្ទៃដីប្រហែលជា 4 អេឃើ ។ បន្ទាប់មក អ្នកត្រូវការកន្លែងចតរថយន្ត រថយន្តថយក្រោយ តំបន់ទ្រនាប់ ការធ្វើចរាចរណ៍ (ឧទាហរណ៍ : ដែលអនុញ្ញាតឱ្យរថយន្តបើកចូល/ជុំវិញបរិវេណបាន) ព្រមទាំងកន្លែងបង្ហូរទឹកចេញ ។ ចំនុចបន្ថែមផ្សេងទៀត ត្រូវការកន្លែងដែលមានទំហំប្រហែលជា 70% ដែលទាមទារឱ្យយើងមានផ្ទៃដីចំនួន 7 អេឃើ ។ ទាំងនេះគឺជាការប៉ាន់ស្មានជាបឋមតែប៉ុណ្ណោះ ហើយនិងត្រូវកែសម្រួលឡើងវិញ ពេលដែលគម្រោងឈានទៅដំណាក់កាលបន្ទាប់ ។

**8. តើក្រុងនឹងបន្តប្រើប្រាស់ពន្ធនាគារ Yakima ឬទេ ?**
កុងត្រាបច្ចុប្បន្នរបស់ក្រុងជាមួយនឹងខោនធី Yakima នឹងត្រូវចប់នៅឆ្នាំ 2010 ហើយក្រុងអាចចចារសុំបន្តរហូតដល់ឆ្នាំ 2012 ។ យើងពេញចិត្តទៅនឹងការប្រើប្រាស់ពន្ធនាគារ Yakima ដើម្បីដាក់ទណ្ឌិត ប៉ុន្តែ ច្បាស់ណាស់ថាមិនមែនជាដំណោះស្រាយរយៈពេលយូរអង្វែងឡើយ ចំពោះសេចក្តីត្រូវការពន្ធនាគាររបស់យើង ។ វាដូចជាឆាប់ពេកក្នុងការនិយាយពីអ្វីដែលនឹងកើតឡើងក្រោយឆ្នាំ 2010 ។

**9. តើអ្នកបាននិយាយទៅកាន់នរណាខ្លះក្នុងសហគមន៍ ? យើងលឺថា អ្នកបានសំភាសន៍ប្រជាពលរដ្ឋ ។ តើមានរឿងអ្វីខ្លះ ហើយតើអ្នកបានលឺអ្វីខ្លះ?**

យើងបានសំភាសន៍ប្រធានសហគមន៍ចំនួន 50 នាក់ ដើម្បីប្រមូលគំនិត និងព័ត៌មានពីពួកគេ ស្តីពីការសាងសង់ពន្ធនាគារថ្មីមួយ ។ អ្នកទាំងនោះសុទ្ធតែជាអ្នកតំណាងឱ្យក្រុម ដែលរាប់ចាប់ពីក្រុមប្រឹក្សាសង្កាត់ ដល់ក្រុមតំណាងផលប្រយោជន៍សហគមន៍ទាំងមូល ។ កិច្ចពិភាក្សានេះពិតជាមានប្រយោជន៍ខ្លាំងណាស់ ហើយបានផ្តល់ឱ្យពួកយើងនូវគំនិតល្អៗជាច្រើន ។ បញ្ហាភាគច្រើនដែលបានលើកឡើង គឺបានឆ្លុះបញ្ចាំងនៅក្នុងឯកសារសំនួរ និងចម្លើយនេះ ហើយនិងបន្តជួយ ត្រួសត្រាយផ្លូវសំរាប់ពួកយើងក្នុងដំណើរការនេះ ។ ចំពោះរបាយការណ៍ស្តីពីបទសំភាសន៍នេះ មានដាក់នៅក្នុងគេហទំព័រពន្ធនាគារក្រុង : http://www.seattle.gov/municipaljail/

**10. ហេតុអ្វីក៏ទីក្រុង Seattle មិនសាងសង់ពន្ធនាគារក្រៅទីក្រុង ?**

យើងបានចូលរួមនៅក្នុងការសិក្សាជាក់ស្តែង ជាមួយទីក្រុងពីចាប់ពីភាគខាងជើង និងខាងកើតខោនធី King ដើម្បីវាយតម្លៃតុល្យភាព ក្នុងការសាងសង់ពន្ធនាគារបទល្មើសមជ្ឈឹមតែមួយ និងពន្ធនាគារពីរ ។ ក្រុងទាំងអស់ដែលបានចូលរួមនៅក្នុងការសិក្សាជាក់ស្តែងនោះ ត្រូវបានស្នេឱ្យកំណត់ទីតាំងដែលអាចធ្វើការសាងសង់បាន ។ ករណីដែលក្រុងទាំងអស់សំរេចចិត្តធ្វើការរួមគ្នា ដើម្បីសាងសង់ពន្ធនាគារបទល្មើសមជ្ឈឹមតែមួយ ពួកគេត្រូវអង្គុយពិភាក្សាគ្នា ដើម្បីសំរេចចិត្តថាតើកន្លែងណាមួយដែលត្រូវសាងសង់ ។

**11. តើនឹងមានផលប៉ះពាល់បរិស្ថានអ្វីខ្លះ ទៅនឹងគម្រោងសាងសង់ធំបែបនេះ ?**

មានមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលវាចំណាយពេលយូរក្នុងការសាងសង់ពន្ធនាគារ ឬគម្រោងសាធារណៈផ្សេងទៀត គឺថា គម្រោងធំៗ ត្រូវឆ្លងកាត់ការត្រួតពិនិត្យពីបញ្ហាបរិស្ថាន និងការការពារជាច្រើនរួមមាន State Environmental Protection Act (SEPA) [ច្បាប់ការពារបរិស្ថានរបស់រដ្ឋ] ផ្លូវការ និងដំណើរការ Environmental Impact Statement (EIS) [របាយការណ៍ផលប៉ះពាល់បរិស្ថាន] ។ រហូតដល់ដំណើរនោះត្រូវបានបញ្ចប់ ហើយយើងនឹងជ្រើសរើសទីតាំងមួយ បន្ទាប់មករៀបចំប្លង់សាងសង់តែម្តង វាមិនអាចទៅរួចឡើយក្នុងការនិយាយថា មានផលប៉ះពាល់អ្វីខ្លះអាចកើតឡើង ។

**12. ហេតុអ្វីក៏យើងមិនផ្លាស់ប្តូរច្បាប់ស្តីគ្រឿងញៀន និងគោលនយោបាយជំនួសវិញ ?**

ក្រុងត្រូវតែមានផែនការថាតើខ្លួននឹងចាប់អ្នកប្រព្រឹត្តល្មើសដោយរបៀបណា ដោយផ្អែកទៅលើអ្វីដែលច្បាប់បានចែង ក្នុងពេលបច្ចុប្បន្ន ដោយមិនត្រូវផ្អែកទៅលើអ្វីដែលនឹងមាននោះឡើយ ។ ច្បាប់ពាក់ព័ន្ធទៅនឹងការសេពគ្រឿងញៀន ត្រូវបានចែងយ៉ាងទូលំទូលាយដោយច្បាប់រដ្ឋ ដែលកំណត់ជម្រើសរបស់ក្រុង ។ ក្រៅពីនេះ ទោះបីជាយើងឈប់ដាក់ពន្ធនាគារ ចំពោះជនទាំងឡាយណាដែលចោទប្រកាន់ពីបទសេពគ្រឿងញៀនដែលល្មើសមជ្ឈឹមក៏ដោយ វាគ្រាន់តែអាចកាត់បន្ថយចំនួនអ្នកអ្នកទោសតិចជាង 3% ប៉ុណ្ណោះក្នុងពន្ធនាគារ ។ ចំពោះការទទួល និងចែកចាយគ្រឿងញៀន គឺជាបទឧក្រិដ្ឋ ហើយត្រូវតែដោះស្រាយដោយខោនធី King ក្រុងបានប្រមូលឯកសារពាក់ព័ន្ធនឹងករណីគ្រឿងញៀនដែលជាបទល្មើសមជ្ឈឹមបានតិចតួចប៉ុណ្ណោះ ។

**13. តើសង្កាត់ត្រូវបញ្ចេញមតិយោបល់ដោយរបៀបណា ក្នុងការជ្រើសរើសទីតាំង ?**

ផ្នែកមួយនៃអ្វីដែលយើងកំពុងតែធ្វើបច្ចុប្បន្ន គឺកំពុងតែប្រមូលព័ត៌មានពីប្រជាពលរដ្ឋក្នុងសង្កាត់ ដូច្នេះយើងអាចដឹងបានកាន់តែច្បាស់ពីកង្វល់ និងតម្រូវការរបស់ពួកគេ ។ សាធារណៈជន នឹងមានឱកាសច្រើនក្នុងការផ្តល់ជាយោបល់ត្រឡប់ ដែលមានចាប់ពីវេទិកាសាធារណៈ រហូតដល់ផ្ញើជាមតិយោបល់តាមរយៈគេហទំព័រពន្ធនាគារក្រុង ។ ចុងក្រោយ ក្រុមប្រឹក្សាក្រុង នឹងរៀបចំសវនាការ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងសង្កាត់ និងអ្នកផ្សេងទៀតបានបញ្ចេញទស្សនៈរបស់ខ្លួន ។ ប៉ុន្តែ យើងគួរគត់សម្គាល់ជាសំខាន់ថា ក្រុងត្រូវតែសាងសង់ពន្ធនាគារនៅកន្លែងណាមួយ ។ យើងគ្មានជម្រើសឡើយ

ទៅនឹងសំនួរទាំង នោះ ។ បញ្ហារបស់យើង គឺត្រូវស្វែងរកទីតាំងសមស្របបំផុត និងធ្វើអ្វីដែលយើងអាចធ្វើទៅបាន ដើម្បីកាត់បន្ថយផលប៉ះពាល់ ដែលអាចកើតមានឡើង ។ ដោយមិនគិតដល់ទីតាំងចុងក្រោយដែលត្រូវសាងសង់ពន្ធនាគារក្រុង ក្រុង Seattle នឹងប្តេជ្ញាសាងសង់ពន្ធនាគារមួយ ដែលល្អបំផុត និងធ្វើឱ្យទៅជាសង្កាត់មួយដែលប្រកបដោយសុវត្ថិភាព ។

### 14. តើក្រុងត្រូវការសាងសង់ពន្ធនាគារធំប៉ុណ្ណា ?

បច្ចុប្បន្ន មានមនុស្សចំនួន 300 នាក់មកពីទីក្រុង ដែលត្រូវចោទប្រកាន់ និងកាន់ទោសពីបទល្មើសមជ្ឈឹមនៅក្នុងពន្ធនាគារខោនធី King ។ ការសិក្សាស្រាវជ្រាវឯករាជ្យមួយ បានរកឃើញថា ដើម្បីទប់ទល់ទៅនឹងកំណើននោះ ប៉ុន្តែក៏ត្រូវពិចារណាឱ្យបានស៊ីជម្រៅផងដែរលើជម្រើសដាក់ពន្ធនាគារ នឹងមានទណ្ឌិតជាមធ្យមចំនួន 383 នាក់ នៅឆ្នាំ 2026 ។ ចំពោះចំនួនបន្ទប់ ដែលត្រូវការដាក់ទណ្ឌិតទាំងនេះ គឺកើនឡើងចំនួន 15% ដើម្បីឆ្លើយតបទៅនឹងកត្តាកំណើន កប់ពពកនេះ (ឧទាហរណ៍ : នៅចុងសប្តាហ៍ និងរដូវក្តៅ មានចំនួនខ្ពស់ជាងគេ នៅថ្ងៃធ្វើការធម្មតា និងរដូវរងារមានចំនួនតិចជាង) ។ ក្រុងរំពឹងថានឹងសាងសង់ពន្ធនាគារក្រុងមួយដែលមាន 445 បន្ទប់ ។ បើតាមការប្រៀបធៀបពន្ធនាគារខោនធី King នៅតំបន់ប្រជុំជនក្រុង Seattle មានលទ្ធភាពផ្ទុកទណ្ឌិតចំនួន 1,697 នាក់ ។

### 15. តើការសាងសង់នេះ មានការប៉ះពាល់ដល់អនិតិជនឬទេ ?

មិនប៉ះពាល់ទេ ។ វាប៉ះពាល់តែមនុស្សពេញវ័យដែលប្រព្រឹត្តិបទល្មើសមជ្ឈឹមតែប៉ុណ្ណោះ ។ ខោនធី King បន្តឃាត់ខ្លួនអនិតិជននៅក្នុង Youth Service Center ។

### 16. ចុះការរត់គេចចេញវិញ ? តើក្រុងនឹងការពារសង្កាត់ពីអ្នករត់គេចចេពីពន្ធនាគារ ដោយរបៀបណា ?

រឿងរត់ចេញពីពន្ធនាគានេះ វាជារឿងកម្រណាស់ ។ គ្មានទណ្ឌិតណាមួយត្រូវជាប់លើសពីមួយឆ្នាំនោះទេ ហើយជាមធ្យមទណ្ឌិតបទល្មើសមជ្ឈឹមជាប់ក្នុងពន្ធនាគារតែរយៈពេលបួនប្រាំថ្ងៃប៉ុណ្ណោះ ។ តាមពិតទៅ គ្មានករណីរត់គេចណាមួយកើតមានឡើយក្នុងពន្ធនាគារខោនធី King ក្នុងរយៈពេល 10 ឆ្នាំចុងក្រោយនេះ ។

### 17. តើមានរឿងអ្វីកើតឡើង ពេលទណ្ឌិតត្រូវបានលែងគ្រប់ពេលទាំងយប់ទាំងថ្ងៃ ?

ចំពោះការអនុវត្តបច្ចុប្បន្ន គឺត្រូវដោះលែងជនទាំងទាំងឡាយណាដែលដល់ថ្ងៃត្រូវចេញនៅម៉ោង 8 ព្រឹក ទោះបីជាច្បាប់តម្រូវឱ្យទណ្ឌិតដែលព្យួរទោស ត្រូវតែដោះលែងនៅពេលប្រកាសក៏ដោយ ។ ក្រុងកំពុងតែរកវិធីដើម្បីការពារតំបន់ជុំវិញពន្ធនាគារ រួមទាំងសេវា និងការដឹកជញ្ជូនជនដែលត្រូវបានដោះលែង ក៏ដូចជារកវិធីដើម្បីធានាពីសុវត្ថិភាពសាធារណៈផងដែរ ។ ព្រោះថា ក្រុងនឹងជាម្ចាស់នៅលើពន្ធនាគារនោះ ខ្លួននឹងអាចរៀបចំគោលនយោបាយដោះលែងនោះ ។

### 18. តើមាននឹងមានអ្វីកើតឡើងនៅកន្លែងពន្ធនាគារ? តើនឹងមានបន្ទប់កាត់ក្តីមែនទេ ? ចុះការិយាល័យសំរាប់មេធាវី? តើការកាត់ក្តីមានចតឬទេ ?

ក្រុងរៀបចំប្លង់ពន្ធនាគារនៅពេលណាដែលខ្លួនជ្រើសរើសទីតាំងរួចរាល់ ។ វាពិតជាលឿនពេក ក្នុងការនិយាយឱ្យច្បាស់ថានឹងមានរឿងអ្វីខ្លះនៅទីនោះ ទោះបីជាយើងអាចនិយាយថា ពន្ធនាគារនឹងអាចដាក់ទណ្ឌិតបានចំនួន 445 នាក់ និងអាចផ្តល់បន្ទប់ប្រជុំមួយសំរាប់មេធាវី និងទណ្ឌិតដែលពួកគេតំណាងឱ្យ ។ សហគមន៍ក៏មានឱកាសផ្តល់ព័ត៌មានផងដែរក្នុងដំណើរការទាំងមូល ។

### 19. តើក្រុងកំពុងតែពិចារណាពីការដាក់រួមគ្នានូវប៉ុស្តិ៍ប៉ូលីស និងពន្ធនាគារមែនទេ ? ឬអាចបន្ថែមប៉ុស្តិ៍មួយទៀត ? ប្រសិនបើពន្ធនាគារស្ថិតនៅជិត វាពិតជាអាចជួយបានច្រើន ប្រសិនបើមានវត្តមានប៉ូលីសច្រើន ។

ការដាក់ប៉ុស្តិ៍ប៉ូលីស គឺជាដំណើរការដាច់ដោយឡែកពីការស្វែងរកទីតាំងសំរាប់ពន្ធនាគារក្រុង ។ ជាធម្មតា វត្តមានប៉ូលីសត្រូវបង្កើតនៅក្នុងបរិវេណពន្ធនាគារ ទោះបីជាប៉ុស្តិ៍ប៉ូលីស ត្រូវដាក់ ឬមិនដាក់បន្ថែមក៏ដោយ ។

**20. តើក្រុងត្រូវដោះស្រាយជាមួយនឹងកំណើនធ្វើដំណើរតាមរថយន្តដោយរបៀបណា ប្រសិនបើពន្ធនាគារសាងសង់ក្រៅទីប្រជុំជន ? វាហាក់ដូចជាមិនអំណោយផលសោះចំពោះបរិស្ថាន ដោយត្រូវឱ្យមន្ត្រីរាជការធ្វើដំណើរឆ្ងាយពីផ្លូវ និងធ្វើឱ្យសហគមន៍គ្មានសុវត្ថិភាព នៅចំនុចពន្ធនាគារ ។**

ក្រុងនឹងស្វែងរកបញ្ហាពីការធ្វើដំណើរ ដូចដែលខ្លួនបានព្រាង Environmental Impact Statement (របាយការណ៍ផល ប៉ះពាល់បរិស្ថាន) ដែលជាផ្នែកមួយនៃដំណើរការ SEPA ផ្លូវការ ។ កិច្ចប្រជុំជាសាធារណៈជាច្រើន ដែលបានផ្តោតសំខាន់ជា ពិសេសទៅលើបញ្ហា SEPA ដូចជាការធ្វើដំណើរជាដើម នឹងត្រូវបានរៀបចំឡើងនៅចុងរដូវក្តៅ នាដើមរដូវស្លឹកឈើជ្រុះឆ្នាំនេះ ។ ពន្ធនាគារដាច់ដោយឡែកនេះ មិនមានការធ្វើចរាចរច្រើនដូចមណ្ឌលយុត្តិធម៌ដែលមានតុលាការដូចជាមណ្ឌលមួយនៅ Kent នោះទេ ។ ជាធម្មតាពន្ធនាគារដាច់ដោយឡែកនេះ មានប៉ូលីសដឹកជញ្ជូនអ្នកទោស មេធាវី និងការមកជួបរបស់គ្រួសារ ។ បញ្ហាចរាចរជាក់លាក់ នឹងត្រូវបានបង្ហាញពេលដែលមណ្ឌលត្រូវបានគូសគ្រោងឡើង ហើយផែនការប្រតិបត្តិការត្រូវបានបង្កើតឡើង ។

**21. ខ្ញុំបានលឺថា ក្រុមប្រឹក្សាខោនធី និងមន្ត្រីកែប្រែនិយាយថា រដ្ឋមានបំណងពន្យាកាលបរិច្ឆេទផុតកំណត់ និងបង្កើតដំណោះស្រាយថ្នាក់តំបន់មួយ ដូច្នេះទីក្រុងផ្សេងៗមិនចាំបាច់សាងសង់ពន្ធនាគារឡើយ ។ ចុះហេតុអ្វីអ្នកនៅតែបន្តសាងសង់ពន្ធនាគារក្រុងទៀត? តើអ្នកមានពិភាក្សាជាមួយខោនធីទេពីបញ្ហានេះទេ ?**

ក្រុងមិនមានបំណងសាងសង់ពន្ធនាគារក្រុងឡើយ ។ ក្រុងរីករាយនឹងបន្តធ្វើការងារជាមួយនឹងខោនធី King លើការដាក់ជនល្មើសក្នុងពន្ធនាគារ ។ ខោនធី King បានទំនាក់ទំនងជាមួយនឹងទីក្រុងផ្សេងៗ ដែលគ្មានបន្ទប់ពន្ធនាគារ នឹងត្រូវជាទីក្រុងដែលត្រៀមខ្លួនដាក់អ្នកទោសនៅឆ្នាំ 2013 ។ ប្រសិនបើខោនធីមានជម្រើសផ្សេងទៀតស្នើឡើង ដោយរួមទាំងការពន្យាកាលបរិច្ឆេទផុតកំណត់ ឬពង្រីក Regional Justice Center ឬសាងសង់ពន្ធនាគារភូមិភាគមួយ ក្រុងពិតជារីករាយនឹងធ្វើការងារជាមួយនឹងខោនធីលើជម្រើសទាំងនោះ ។ ទោះយ៉ាងណា កុងត្រាបច្ចុប្បន្នបានបង្ខំយើងឱ្យបន្តរៀបចំផែនការបច្ចុប្បន្នរបស់យើង ព្រោះក្រុងតម្រូវឱ្យសាងសង់ពន្ធនាគារដាក់អ្នកទោសរបស់ខ្លួនទៅតាមផ្លូវច្បាប់ ។ ទោះបីជាដំណោះស្រាយតំបន់ត្រូវបានរកឃើញក៏ដោយ ក៏មានគេនឹងសាងសង់ពន្ធនាគារថ្មី នៅកន្លែងណាមួយក្នុងខោនធី King ជាមិនខាន (ហើយប្រហែលជានៅក្រុង Seattle តែម្តង) ។

**22. តើក្រុងបានបង្រួមបួនទីតាំង ដោយមិនពិចារណាថាតើទីតាំងនោះជិតទៅនឹងសាលារៀន សួនច្បារ និងកន្លែងរស់នៅដោយរបៀបណា ? តើក្រុងអាចបង្រួម 35 ទីតាំង ឱ្យទៅជា 11 ទីតាំង ទៅបួនទីតាំងបានដោយរបៀបណា?**

យើងកំពុងតែពិចារណាលើកត្តាជាច្រើន ក្នុងដំណើរការសំរេចចិត្តលើទីតាំង ។ យើងត្រូវការកំណត់ទីតាំងទាំងមានទំហំធំល្មម និងមានលក្ខណៈអំណោយផលក្នុងការសាងសង់ពន្ធនាគារ ។ មុនពេលសម្រេចចិត្តជាលើកចុងក្រោយ យើងនឹងពិភាក្សាលើកត្តាផ្សេងទៀត រួមមានគម្លាតទៅនឹងកន្លែងរស់នៅ សួនច្បារ និងសាលារៀន ក៏ដូចជាផលប៉ះពាល់បរិស្ថាន ។ វាពិតជាពិបាកណាស់ក្នុងការសាងសង់ពន្ធនាគារឱ្យនៅដាច់ដោយឡែកពីទីប្រជុំជនកុះករ ដូចទីក្រុង Seattle នេះ ។ ផែនទីបានបង្ហាញថា វាពិតជាពិបាកខ្លាំងណាស់ក្នុងការស្វែងរកទីតាំងដែលមានគម្លាតមួយម៉ាយពីសាលារៀន ។ យើងសូមស្វាគមន៍រាល់ព័ត៌មានទាំងអស់ពីសង្កាត់ លើកត្តាកំណត់ទីតាំងដែលយើងកំពុងតែពិចារណា ។

**23. តើក្រុងអាចប្រើប្រាស់អំណាចត្រួតត្រា ដើម្បីយកដីដែរឬទេ ?**

នេះគឺជាជម្រើសមួយ ទោះយ៉ាងណា ក្រុងមិនចង់ប្រើប្រាស់អំណាចត្រួតត្រាឡើយ បើអាចទៅរួច ។

**24. តើក្រុងកំពុងតែពិចារណាដោយរបៀបណាពីទីតាំងដែលឆ្ងាយពីសាលារៀនមួយម៉ាយ ?**

ស្ទើរតែទីក្រុងទាំងមូល គឺស្ថិតនៅក្នុងចម្ងាយពីសាលារៀនមួយម៉ាយ ។ យើងកំពុងតែពិចារណាគម្លាតពីសាលារៀន និងសួនច្បារ និងមើលពីចម្ងាយ ក៏ដូចជាមើលនៅក្នុងផែនទីភូមិសាស្ត្រ ។ យើងប្តេជ្ញាថា នឹងសាងសង់ពន្ធនាគារក្រុងមួយដែលមានសុវត្ថិភាព និងជាសង្កាត់មួយដែលល្អ ។

**25. តើពន្ធនាគារនេះ នឹងស៊ីសង្វាក់គ្នាទៅនឹងគម្រោង របៀបវារៈវិធានការណ៏ និងការរៀបចំភូមិទីក្រុងរបស់សង្កាត់ដោយរបៀបណា?**

គ្មានសង្កាត់ណាមួយបានគិតពីពន្ធនាគារថ្មីនោះទេ ពេលរៀបចំប្លង់របស់ខ្លួន ។ ពេលទីតាំងចុងក្រោយត្រូវបានជ្រើសរើស យើងនឹងធ្វើការជាមួយនឹងសហគមន៏ ថាតើពន្ធនាគារថ្មីនេះនឹងប៉ះពាល់ដល់គម្រោងនោះដូចម្តេចខ្លះ ។

**26. តើពេលណាទើបគេធ្វើការសម្រេចចិត្ត ?**

យើងដូចជានៅដើមទីណាស់ ក្នុងដំណើរការដ៏យូរអង្វែងនេះ ដែលនឹងរួមបញ្ចូលឱកាសសម្រាប់ទាំងមតិយោបល់សាធារណៈ និងការពិនិត្យទៅលើបរិស្ថាន ។ ក្រុមប្រឹក្សាក្រុងរំពឹងថា នឹងធ្វើការសម្រេចចិត្តចុងក្រោយលើទីតាំងនៅដើមឆ្នាំ 2009 ។

**27. តើក្រុងកំពុងតែពិចារណាពីផលប៉ះពាល់ ដែលនឹងកើតលើតម្លៃទ្រព្យសម្បត្តិ និងមូលដ្ឋានពន្ធដែរឬទេ ?**

ការសិក្សាជាច្រើនបានរកឃើញថា មានពន្ធនាគារថ្មីៗជាច្រើននៅទីក្រុងផ្សេងៗទូទាំងប្រទេស មានផលប៉ះពាល់តិចតួចបំផុតលើតម្លៃទ្រព្យសម្បត្តិ ក្នុងសង្កាត់ទាំងមូល ដែលនៅជិតពន្ធនាគារបំផុត ។ ការសិក្សាមួយធ្វើឡើងដោយ Department of Justice (ក្រសួងយុត្តិធម៌) បានមើលទៅលើសហគមន៏ចំនួនប្រាំពីរក្នុងរដ្ឋខុសៗគ្នា ដែលមានពន្ធនាគារ ហើយបានប្រៀបធៀបទៅនឹងសហគមន៏ប្រដៀងគ្នា ដែលគ្មានពន្ធនាគារ ។ ការសិក្សាបានរកឃើញថា តម្លៃលក់ទ្រព្យសម្បត្តិមិនមានភាពខុសគ្នាខ្លាំងរវាងសហគមន៏ដែលមានពន្ធនាគារ និងសហគមន៏ដែលគ្មានពន្ធនាគារ ។ ការសិក្សានោះបានបង្ហាញទៀតថា អត្រាបទល្មើសមានកម្រិតប្រហាក់ប្រហែលគ្នា ឬអាចទាបជាង នៅក្នុងសហគមន៏ដែលមានពន្ធនាគារ ។

**28. ពេលណាអ្នកសាងសង់វារួចរាល់ហើយ តើមូលហេតុអ្វីដែលធ្វើឱ្យអ្នកមិនពង្រីកពន្ធនាគារនេះ ឬត្រូវប្រើប្រាស់វាសំរាប់ដាក់អ្នកទោសដែលមានចំនួនហូរហៀរ ដែលមានគ្រោះថ្នាក់ កាន់តែខ្លាំងឡើង ?**

ផ្អែកលើច្បាប់រដ្ឋ រដ្ឋនៅតែមានសមត្ថកិច្ចដាក់អ្នកទោសសង្ស័យ និងអ្នកប្រព្រឹត្តិល្មើស ។ ក្រុងគ្មានសមត្ថកិច្ចដាក់ជនល្មើសក្នុងពន្ធនាគារក្រុងរបស់ខ្លួនឡើយ ។ យើងរំពឹងថា ពន្ធនាគារដែលមាន 445 បន្ទប់ ដែលត្រូវបានសាងសង់លើផ្ទៃដីពី 7 ទៅ 10 អេឃើ នឹងមានលក្ខណៈទូលាយ សមស្របទៅនឹងតម្រូវការបទល្មើសមធ្យមរបស់ក្រុង យ៉ាងហោចណាស់នៅឆ្នាំ 2025 ។

**29. តើកម្មវិធីកាត់ទោសជាបន្តបន្ទាប់ នឹងកើតមាននៅក្នុងពន្ធនាគារទេ ដូច្នេះ អ្នកដែលត្រូវសរសេររបាយការណ៏ពេលថ្ងៃៗ ក៏មកសង្កាត់នេះផងដែរ?**

គ្មានគម្រោង ផ្លាស់ប្តូរការរាយការណ៏ពេលថ្ងៃ និងកម្មវិធីផ្សេងទៀត ពីទីតាំងទីប្រជុំជនបច្ចុប្បន្ន ទៅទីតាំងពន្ធនាគារក្រុងឡើយ ។

**30. តើមានឧទាហរណ៏ណាបញ្ជាក់ថាពន្ធនាគារ មានឥទ្ធិពលជាវិជ្ជមានទេ ឧទាហរណ៏ : បង្កើតការងារកាន់តែច្រើនជាដើម? តើមានសារៈប្រយោជន៏អ្វីខ្លះ ដែលក្រុងផ្តល់ឱ្យ ?**

ពន្ធនាគារមានឥទ្ធិពលជាវិជ្ជមានទៅលើសេដ្ឋកិច្ចដូចជា តួនាទីជាមន្ត្រីកែប្រែ ទទួលបានប្រាក់បៀវត្សរ៏ខ្ពស់ និងទទួលបានអត្ថប្រយោជន៏ល្អជាច្រើន ។ ចំពោះការងារពាក់ព័ន្ធទៅនឹងការសាងសង់ ក៏អាចមានផល់ប៉ះពាល់ជាវិជ្ជមានផងដែរដល់សេដ្ឋកិច្ច ។ វាឆាប់ពេកហើយក្នុងការចាប់ផ្តើមកំណត់ឱ្យច្បាស់លាស់ពីអត្ថប្រយោជន៏នានា ដែលក្រុងអាចផ្តល់ឱ្យចំពោះ

អត្ថប្រយោជន៍ទាំងនោះ នឹងកើតមានជាក់លាក់ ទៅលើទីតាំង និងសហគមន៍ដែលជ្រើសរើស ។ ឧទាហរណ៍ ៖ ពេលដែលខោនធី King ស្ថិតនៅក្នុង Regional Justice Center (RJC) ក្នុងខោនធី Kent ខោនធីមិនយល់ព្រមផ្តល់សេវាចំនីអាហារក្នុងទីតាំងឡើយ ដល់បុគ្គលិក និងក្រុមប្រឹក្សតុលាការ ដូច្នេះមានតែភោជនីយដ្ឋាន និងហាងក្នុងតំបន់នោះ ហើយដែលទទួលបានអត្ថប្រយោជន៍ ។

RJC នេះហើយជាឧទាហរណ៍ ដែលពន្ធនាគារអាចក្លាយទៅជាសង្កាត់មួយល្អ ។ Kent Commons ( មជ្ឈមណ្ឌលបង្កើតឡើងថ្មី) គឺនៅជិតគ្នាទៅនឹង RJC ។ ទីលាន ice hockey ក៏កំពុងតែសាងសង់នៅទល់មុខ ដែលជាអតីតដីសំរាប់លេងបាល់ ។ Kent Station ( ជារោងភាពយន្តច្រើនបញ្ចូនគ្នា ហាងលក់រាយ ។ល ។) គឺស្ថិតនៅក្នុងប្លុកទាំងពីរនៃ RJC ។ ទីក្រុង Seattle បានប្តេជ្ញានឹងក្លាយទៅជាសង្កាត់មួយដែលលក្ខណៈល្អ ទោះបីជាពន្ធនាគារក្រុង មានទីតាំងនៅកន្លែងណាក៏ដោយ ។

**31. ប្រសិនបើក្រុងសាងសង់ពន្ធនាគារនៅទីតាំងណាមួយ នោះមានន័យថាការិយាល័យបង់ប្រាក់ធានា និងសេវាកម្មតូចតាចផ្សេងទៀត នឹងត្រូវរីកដុះដាលជុំវិញនោះមែនទេ ?**

ទីក្រុង Seattle បានពិនិត្យទីក្រុង Issaquah និង Renton រួចហើយ ទីក្រុងទាំងពីរនេះមានពន្ធនាគារដែលមាន 50 បន្ទប់ ហើយបានសិក្សាឃើញថា គ្មានការិយាល័យបង់ប្រាក់ធានាណាមួយនៅជុំវិញនោះឡើយ ។ ទណ្ឌិតប្រើប្រាស់ការិយាល័យបង់ប្រាក់ធានា ដែលមាននៅក្នុងទីប្រជុំជន Seattle និង Kent ។ ប្រសិនបើទណ្ឌិតមានបំណងបង់ប្រាក់នៅបន្ទប់ឃុំ ពួកគេត្រូវតែទូរស័ព្ទទៅការិយាល័យបង់ប្រាក់ធានា ហើយបន្ទាប់មកនឹងមានភ្នាក់ងារមកដល់ពន្ធនាគារជួបជាមួយនឹងទណ្ឌិត ។ ប្រហែលជា 10% ទណ្ឌិតបទល្មើសមជ្ឈឹមនៅ Seattle ត្រូវបានដោះលែង ដោយសារពួកគេប្រើប្រាស់ក្រុមហ៊ុនបង់ប្រាក់ធានា បង់ប្រាក់ក្នុងនាមខ្លួន ។